# អារម្ភកថា

នយោបាយឈ្នះ-ឈ្នះ ដែលបានបញ្ចប់សង្គ្រាមស៊ីវិលទាំងស្រុងនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ន ធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាព ការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការពង្រឹងនីតិរដ្ឋ និងសន្តិសុខគតិយុត្ត។ ដើម្បីសម្រេចបាននូវការពង្រឹងនីតិរដ្ឋ និងសន្តិសុខគតិយុត្ត ក្រសួង-ស្ថាប័នជាច្រើនត្រូវបានបង្កើតឡើង ក្នុងនោះក៏មានក្រុមប្រឹក្សាអ្នកច្បាប់ ដែលត្រូវបានបង្កើតតាំងពីឆ្នាំ១៩៩៤ បានរួមចំណែកបំពេញតួនាទីយ៉ាងសកម្ម និងពេញលេញ បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជា ទទួលបានសន្តិភាពពេញលេញតាមរយៈនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

ក្រុមប្រឹក្សាអ្នកច្បាប់ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ១៣ អនក្រ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៤ និងបន្ទាប់មកត្រូវបានកែសម្រួលដោយអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ។

**ក្រុមប្រឹក្សាអ្នកច្បាប់មានភារកិច្ចដូចតទៅ៖**

-សិក្សាស្រាវជ្រាវដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលនិងផ្នែកឯកជន ដើម្បីលើកគម្រោងកសាងច្បាប់ឬលិខិតបទដ្ឋានគតិយុត្តថ្មីៗដែលមានការចាំបាច់សម្រាប់បម្រើសកម្មភាពរាជរដ្ឋាភិបាល

-សិក្សានិងតាមដានអត្ថបទច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលត្រូវបានប្រកាសឱ្យប្រើ ដែលលែងសមស្របនឹងសភាពការណ៍ជាក់ស្តែង ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលធ្វើវិសោធនកម្ម ឱ្យទាន់ពេលវេលានិងស្របតាមស្ថានភាពវិវត្តន៍នៃប្រទេសជាតិ

-សិក្សានិងផ្តល់យោបល់ជូនក្រសួង ស្ថាប័ន និងគណៈរដ្ឋមន្ត្រី អំពីសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយជាមួយអន្តរជាតិដែលបណ្តាក្រសួងស្ថាប័នផ្ញើមកសុំការសម្រេចពីគណៈរដ្ឋមន្ត្រី

-ជួយទីស្តីការគណៈរដ្ឋមន្ត្រីក្នុងការចាត់ចែងផ្ញើសេចក្តីព្រាងច្បាប់ជូនស្ថាប័ននីតិប្បញ្ញត្តិពិនិត្យ និងអនុម័ត និងសម្របសម្រួលឱ្យមានតំណាងរាជរដ្ឋាភិបាលទៅការពារសេចក្តីព្រាងច្បាប់នៅស្ថាប័ននីតិប្បញ្ញត្តិ

-ជួយទីស្តីការគណៈរដ្ឋមន្ត្រីក្នុងការរៀបចំបែបបបទថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់

-ជួយទីស្តីការគណៈរដ្ឋមន្ត្រីដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំសេចក្តីព្រាងចម្លើយរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** តបនឹងសំណួររបស់តំណាងរាស្ត្រ ស្របតាមមាត្រា៩៦នៃរដ្ឋធម្មនុញ្ញ

-តាមដាន ឃ្លាំមើលលើការអនុវត្តនិងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត។

ជារួម សកម្មភាពការងាររបស់ក្រុមប្រឹក្សាអ្នកច្បាប់ បានចូលរួមចំណែកលើវិស័យយុត្តិធម៌ឱ្យបានល្អប្រសើរក្នុងដំណើរការពង្រឹងនីតិរដ្ឋស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សំដៅធ្វើយ៉ាងណាឱ្យមានសង្គតិភាពគតិយុត្តក្នុងព្រះរាជាណាចក្រកម្ពុជា។